ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៩២
ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២

សាលដីកា
លេខៈ ២៤៣
ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៨២"ដ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៩២ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទៈ ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រានៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនត្រូវចោទ

១-ឈ្មោះ [redacted] ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ៣ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៤៧ ផ្លូវលេខ៥ ក្រុមទី១ ភូមិ៣ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨។

-មានមេធាវីលោក [redacted]



Scanned by CamScanner

69/6

២-ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃភូមិទី២ ក្រុមទី១ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ របររកស៊ីជាងឈើ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] " ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨។

៣-ឈ្មោះ [redacted] ហៅ ពីន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនិងទីលំនៅសព្វថ្ងៃផ្ទះលេខ ១២០៣ ផ្លូវលេខ៥ ក្រុមទី៥ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] " ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ជាចុងបណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ៤២ឆ្នាំ មានទីលំនៅផ្ទះលេខ៣១៦ ផ្លូវលេខ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-តាមពាក្យបណ្ដឹងចុះ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលច្រាំងចំរេះទី១ ថាកាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ នៅវេលាម៉ោង២១និង៤៥នាទី នៅចំណុចផ្ទះលេខ៣១៦ ផ្លូវលេខ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាដើមបណ្ដឹងឈ្មោះ [redacted] ទៅស្ដូត្រធម៌នៅវិហារ ទុកប្រពន្ធ និងកូនសំរាកនៅផ្ទះ ដោយចាក់សោរមិនបានដកហូតកូនសោរ ពេលនោះមានមនុស្សមួយក្រុមមានឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ,ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] បានលូកដៃតាមចន្លោះទ្វារចាក់សោរទ្វារដែលម្ចាស់ភ្លេចដកកូនសោរទុក ហើយចូលក្នុងផ្ទះបានលួចយកទូរស័ព្ទម៉ាកណូគារចំនួន០១គ្រឿង និងដោះយកខ្សែកផ្លាកទីន០១ខ្សែរ ពីកូនដើមបណ្ដឹងកំពុងដេក ពេលនោះកូនដើមបណ្ដឹងបានភ្ញាក់ដឹងខ្លួន ហើយស្គាល់ជនត្រូវចោទម្នាក់ឈ្មោះ [redacted] ហើយបានប្រាប់ទៅដើមបណ្ដឹងដែលជាឪពុក។ លុះដល់ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៨ ដើមបណ្ដឹងបានចាប់ និងនាំឈ្មោះ [redacted] មកអោយសមត្ថកិច្ចតែម្ដង។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ មានពិរុទ្ធភាព គ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ (កំពុងឃុំខ្លួន) ឈ្មោះ [redacted] ភេទប្រុស អាយុ២២ឆ្នាំ (គេចខ្លួន) ឈ្មោះ [redacted] ភេទប្រុស អាយុ១៦ឆ្នាំ (គេចខ្លួន) ឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ (គេចខ្លួន) ឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន) ពីបទ ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅចំណុចផ្ទះលេខ៣១៦ ផ្លូវជាតិលេខ៥ ក្រុម១ ភូមិ២ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ បទល្មើសមានចែងអោយផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។



Scanned by CamScanner

69/5

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៥៦"ក្រ២" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១.ក/-ផ្តន្ទាទោសលើឈ្មោះ [redacted] ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធធានាគារ កំណត់៥ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨។

ខ/-ផ្តន្ទាទោសលើឈ្មោះ [redacted]ភេទប្រុស អាយុ២៥ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ២២ឆ្នាំ ឈ្មោ[redacted]ប្រុស អាយុ២១ឆ្នាំ និងឈ្មោ[redacted] ហៅក្តាម ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់៥ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន។

គ/-ផ្តន្ទាទោសលើឈ្មោះ [redacted]ភេទប្រុស អាយុ១៦ឆ្នាំ ដាក់ពន្ធនាគាកំណត់២ឆ្នាំ ៦ខែ គិតពីថ្ងៃចាប់ឃុំខ្លួនបាន។

ពីបទប្លន់ ប្រព្រឹត្តនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២.ក/-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted]និងឈ្មោ[redacted]ហៅក្តាម និងធ្វើការឃុំខ្លួនឈ្មោះទាំងនោះ នៅពន្ធនាគារ ម១ នៃក្រសួងមហាផ្ទៃ ដើម្បីអនុវត្តទោស។

ខ/-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] និងធ្វើការឃុំខ្លួនឈ្មោះនេះនៅពន្ធនាគារម២ នៃក្រសួងមហាផ្ទៃ ដើម្បីអនុវត្តទោស។

តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៣-វត្ថុតាងគឺ ខ្សែកលោហធាតុ ពណ៌ទង់ដែងចំនួនមួយខ្សែ បន្តោងរូបបេះដូងលោហធាតុពណ៌ទង់ដែងចំនួនមួយ ប្រគល់ឱ្យឈ្មោះ [redacted]ជាម្ចាស់ដើមវិញ។

តាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]កំបាំងមុខជនជាប់ចោទ ឈ្មោះ[redacted] ឈ្មោះ [redacted], ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted]និងដើមបណ្តឹង។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned by CamScanner

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៥៦"ក្រ២" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥៦ ក្រ.២ "ឃ" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ៖

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ហៅពីន ដែលបានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ១៥៦ក្រ២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥៦ក្រ២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូលដដែល។

៣-សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៥៦ក្រ.២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ របស់ឈ្មោ[redacted]ងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៦ក្រ.២"ឃ" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ សូមសភាព្រហ្មទណ្ឌមេត្តាពិនិត្យ ហើយតំកល់ និងរក្សាសាលក្រមដើមទុកជាបានការផ្លូវច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨២"ដ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមច្បាប់។

-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted]ងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោ[redacted]



Scanned by CamScanner

169/3

ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធទាស់គតិច្បាប់។

២-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ហៅពីន ពីបទប្លន់មកជាបទទទួលផលចោរកម្មវិញ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥៦"ក្រ២" ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ និងសាលក្រមព្រហ្មទណ្ឌលេខ៥៦ ក្រ.២ "ឃ" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោ [redacted] ត្រូវកែប្រែជា:

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ អ៊ីស្លាម ដាក់ពន្ធនាគារកំណត់០១ឆ្នាំ គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិ១ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ក្រៅពីនេះរក្សាទុកនៅដដែល។

៤-បន្តឃុំខ្លួនជនជាប់ចោទ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ២០៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨២"ដ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពាររបស់លោក [redacted] មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ ហ៊ឹម វ៉សេត ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ២០៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសទៅនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨២"ដ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។



Scanned by CamScanner

169/7

-បានស្តាប់សាវតាជាតិ និងចំលើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការថា៖ មូលហេតុអ្វីបានអ្នកឯងប្តឹងសាទុក្ខ? ខ្លួនប្តឹងសាទុក្ខដោយសារតែឈ្មោះ[redacted] ត្រូវបានតុលាការលើកលែងចោទប្រកាន់ ការលួចនេះ ខ្លួនមិនបានដឹងទេ គឺឈ្មោះ[redacted]បានហៅខ្លួនទៅផឹកស៊ី រួចក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩។ ខ្លួនមិនបានដឹងពីការលួចនេះទេ ឯឈ្មោះ [redacted]គ្រាន់តែស្គាល់គ្នាជាអ្នកភូមិជាមួយគ្នា។

សំណូមពរ៖ សុំអោយតុលាការលើកលែងចោទប្រកាន់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក [redacted]មេធាវីការពារមេធាវីការពារជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការថា៖ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៩ ម៉ោងប្រហែល៦ ទៅ៧ តាមរបាយការណ៍របស់ប៉ូលិសម៉ោង៩:៤៥នាទីយប់ ហើយក៏បានរបាយការណ៍ថា មានជនជាប់ចោទ៦នាក់ ប៉ុន្តែតាមពិតមានតែ៣នាក់ទេ។[redacted]ជាអ្នកលួច ហើយបាននាំកូនក្តីខ្លួនទៅផឹកស៊ី តែសាលាឧទ្ធរណ៍ កែប្រែឈ្មោះ [redacted]ពីបទប្លន់មកទទួលផលចោរកម្មវិញ ឯកូនក្តីខ្លួនមិនត្រូវបានកែប្រែបទចោទដូច[redacted]ទើបកូនក្តីខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល។ រហូតមកដល់ពេលនេះកូនក្តីខ្លួនបានជាប់ពន្ធនាគារ មានរយៈពេល៤ឆ្នាំហើយ។ ដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាសំរេចដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: មាត្រា៧៩ ការកាប់គាស់ទំលុះទំលាយ និងចូលក្នុងមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារអោយជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ[redacted]ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌតុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន។

-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ចំពោះមុខសវនាការតុលាការកំពូលថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ការធ្វើសកម្មភាពនេះ ឈ្មោះ[redacted] ធ្វើតែម្នាក់ឯងទេ ពេលប្រព្រឹត្តរួច ឈ្[redacted]នមកបបួលខ្លួនទៅផឹកស៊ី ចម្លើយដោះសារ



Scanned by CamScanner

169/1

នេះផ្ទុយពីចម្លើយរបស់ឈ្មោះ [redacted]នាំងណាក់កាលស៊ើបអង្កេតសាកសួរថា ខ្លួនជាអ្នកចូលក្នុងផ្ទះ ហើយជនជាប់ចោទផ្សេងទៀត ដែលក្នុងនោះមានឈ្មោះ [redacted] ជាអ្នកចាំផ្លូវ។ ការដោះសារ របស់ជនជាប់ចោទគ្មានភស្តុតាងដោះបន្ទុកទេ។ ដូច្នេះអាចកំណត់បានថាឈ្មោ[redacted]សហចារី នៃបទល្មើសនេះ។

-យល់ឃើញថា ក្រមព្រហ្មទណ្ឌថ្មីបានចូលជាធរមាន ហើយទណ្ឌកម្មដែលបានកំណត់ក្នុង បទលួចនៃក្រមព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងទណ្ឌកម្ម ដែលបានកំណត់ក្នុងមាត្រា៦ នៃច្បាប់ ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ដូច្នេះគប្បីអនុវត្តតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា សាលដីកាសភាព្រហ្មទណ្ឌលេខ៨២ “ដ” ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ខ្លះ ខុសខ្លះ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ២០៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ [redacted]

២-តម្កល់សាលដីកាសភាព្រហ្មទណ្ឌលេខ៨២“ដ” ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់ សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែទណ្ឌកម្មត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៩២ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ របស់តុលាការ កំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ លើចំណុចស្តីពីទណ្ឌកម្មលើឈ្មោះ[redacted]

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ និងប្រកាស ជាសាធារណៈ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលាដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ១០ ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ១០ ឆ្នាំ២០១៣

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner